ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

*ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦*

## ការពង្រឹងភាពជាដៃគូកសិកម្ម និងអាហាររវាងអូស្ត្រាលី និងកម្ពុជា តាមរយៈផលិតផលលំដាប់ខ្ពស់ និងនវានុវត្តន៍នៃខ្សែច្រវាក់ផ្គត់ផ្គង់

លោកស្រី Tennealle O′Shannessy អ្នកធុរកិច្ចឆ្នើមអូស្ត្រាលីប្រចាំនៅកម្ពុជា ដោយមានការគាំទ្រពីស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា និងគណៈកម្មការពាណិជ្ជកម្ម និងវិនិយោគអូស្ត្រាលី (Austrade) នៅថ្ងៃនេះ បានដឹកនាំគណៈប្រតិភូនៃធុរកិច្ចកសិកម្មឈានមុខគេរបស់អូស្ត្រាលីចំនួន ២៦ ក្រុមហ៊ុន មកកាន់រាជធានីភ្នំពេញ ដែលជាផ្នែកមួយនៃបេសកកម្មផ្សារភ្ជាប់វិស័យកសិកម្ម និងអាហារអូស្ត្រាលី មកកាន់កម្ពុជា និងវៀតណាម។ កម្មវិធីដែលមានរយៈពេល ៥ ថ្ងៃនេះ ចាប់ផ្តើមពីថ្ងៃទី១៥ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ នៅកម្ពុជា និងវៀតណាម ដែលត្រូវបានរៀបចំឡើងក្រោមកម្មវិធីផ្លាស់ប្តូរធុរកិច្ចអូស្ត្រាលី-អាស៊ីអាគ្នេយ៍ (A-SEABX) ដែលនេះគឺជាគណៈប្រតិភូធុរកិច្ចកសិកម្មអូស្ត្រាលីដ៏ធំបំផុតមួយដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជា សបញ្ជាក់ឱ្យឃើញអំពីការកើនឡើងនូវចំណាប់អារម្មណ៍របស់ធុរកិច្ចអូស្ត្រាលីចំពោះទីផ្សារកម្ពុជា។

បេសកកម្មនេះបានចាប់ផ្តើមនៅថ្ងៃនេះនៅរាជធានីភ្នំពេញ ជាមួយនឹងការចុះទៅទស្សនកិច្ចនៅតាមបណ្តាក្រុមហ៊ុនលក់រាយ និងធុរកិច្ចកសិកម្មឈានមុខ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីការវិវត្តនៃទិដ្ឋភាពកសិកម្ម និងអាហារនៅកម្ពុជា។ ទស្សនកិច្ចសិក្សាទាំងនេះបានផ្តល់នូវការយល់ដឹងដ៏មានតម្លៃអំពីខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងស្រុក និន្នាការអ្នកប្រើប្រាស់ និងឱកាសទីផ្សារថ្មីៗដែលកំពុងកើតមាន។ បន្ថែមទៅលើទស្សនកិច្ចសិក្សានេះ កម្មវិធីផ្សារភ្ជាប់វិស័យកសិកម្ម និងអាហារ អូស្ត្រាលី-កម្ពុជា បានប្រមូលផ្តុំថ្នាក់ដឹកនាំធុរកិច្ច សមាគមឧស្សាហកម្ម អ្នកជំនាញកសិកម្ម និងដៃគូសក្តានុពលនានា ដើម្បីជំរុញពាណិជ្ជកម្ម និងការវិនិយោគទ្វេរភាគី ព្រមទាំងស្វែងរកភាពជាដៃគូពាណិជ្ជកម្មថ្មីៗផងដែរ។

គណៈប្រតិភូនេះត្រូវបានបែងចែកជាពីរផ្នែកដែលបំពេញឱ្យគ្នាទៅវិញទៅមក។ ផ្នែកអាហារ និងភេសជ្ជៈ រួមមានក្រុមហ៊ុននាំចេញសាច់លំដាប់ខ្ពស់ គ្រឿងសមុទ្រ ផលិតផលទឹកដោះគោ កសិផល ស្រាទំពាំងបាយជូរ ភេសជ្ជៈ និងអាហារវេចខ្ចប់។ ចំណែកឯផ្នែកខ្សែប្រវាក់ផ្គត់ផ្គង់អាហារ បានប្រមូលផ្តុំទៅដោយធុរកិច្ចកសិកម្មអូស្ត្រាលី ដែលផ្គត់ផ្គង់នូវធាតុចូល បច្ចេកវិទ្យា ចំណេះដឹងបច្ចេកទេស និងនវានុវត្តន៍បច្ចេកវិទ្យាកសិកម្ម ដើម្បីបង្កើនផលិតភាព និរន្តរភាព មានប្រភពដើមច្បាស់លាស់ និងការបង្កើនតម្លៃបន្ថែមនៅទូទាំងខ្សែប្រវាក់តម្លៃកសិកម្ម និងអាហារ។

សេដ្ឋកិច្ចដ៏រស់រវើក និងការពង្រីកវិសាលភាពពាណិជ្ជកម្មរបស់កម្ពុជា បានបង្កើតឱ្យមានកាលានុវត្តភាពយ៉ាងសម្បូរបែបសម្រាប់ភាពជាដៃគូជាមួយអូស្ត្រាលី។ ខណៈដែលអ្នកប្រើប្រាស់នៅទីប្រជុំជនកាន់តែបង្កើនការស្វែងរកផលិតផលអាហារ និងភេសជ្ជៈដែលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងអាចដឹងពីប្រភពច្បាស់លាស់

អូស្ត្រាលីត្រៀមខ្លួនជាស្រេចក្នុងការឆ្លើយតបទៅនឹងតម្រូវការនេះ ជាមួយនឹងផលិតផលលំដាប់ខ្ពស់។ ក្រៅពីវិស័យលក់រាយ អូស្ត្រាលីមានលទ្ធភាពខ្ពស់ក្នុងការគាំទ្រដល់ផលិតកម្មកសិកម្ម និងអាហារក្នុងស្រុករបស់កម្ពុជា រួមទាំងតាមរយៈការផ្តល់នូវគ្រឿងផ្សំគុណភាពខ្ពស់ បច្ចេកវិទ្យាកសិកម្មប្រកបដោយនវានុវត្តន៍ និងដំណោះស្រាយខ្សែប្រវាក់ផ្គត់ផ្គង់អាហារ។ កិច្ចសហការនេះ នឹងជួយពង្រឹងខ្សែប្រវាក់តម្លៃក្នុងស្រុកឱ្យកាន់តែរឹងមាំ ព្រមទាំងបង្កើតបរិយាកាសដ៏ប្រសើរសម្រាប់ជំរុញពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី។

ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា បេសកកម្មនេះបានរំលេចឱ្យឃើញពីកាលានុវត្តភាពកាន់តែប្រសើរឡើងសម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងអាហារ រវាងអូស្ត្រាលី និងកម្ពុជា។ ឯកឧត្តមបានបញ្ជាក់ថា៖ «សេដ្ឋកិច្ចដ៏មានថាមពលរបស់កម្ពុជា និងការរីកចម្រើននៃវិស័យលក់រាយទំនើប កំពុងបង្កើតឱ្យមានតម្រូវការខ្ពស់សម្រាប់ផលិតផលអាហារ និងភេសជ្ជៈដែលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងអាចដឹងពីប្រភពច្បាស់លាស់។ អូស្ត្រាលីមានលទ្ធភាពខ្ពស់ក្នុងការធ្វើជាដៃគូជាមួយកម្ពុជា តាមរយៈការផ្គត់ផ្គង់កសិផលគុណភាពខ្ពស់ និងការចែករំលែកនូវបទពិសោធន៍ជំនាញ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីគាំទ្រដល់វិស័យកសិកម្ម និងអាហារទំនើបប្រកបដោយនិរន្តរភាព។ គំនិតផ្តួចផ្តើមនានាដូចជាបេសកកម្មផ្សារភ្ជាប់វិស័យកសិកម្ម និងអាហារនេះ នឹងជួយតភ្ជាប់ធុរកិច្ចអូស្ត្រាលីជាមួយដៃគូកម្ពុជា ដែលជាការត្រួសត្រាយផ្លូវថ្មីសម្រាប់ពាណិជ្ជកម្ម ការវិនិយោគ និងការផ្លាស់ប្តូរចំណេះដឹងរវាងប្រទេសទាំងពីរ»។

លោកស្រី Tennealle O'Shannessy អ្នកធុរកិច្ចឆ្នើមអូស្ត្រាលីប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា កម្ពុជាផ្តល់នូវកាលានុវត្តភាពដ៏រឹងមាំសម្រាប់ធុរកិច្ចអូស្ត្រាលី ដែលមានបំណងចង់ពង្រីកវត្តមានពាណិជ្ជកម្ម និងការវិនិយោគរបស់ខ្លួន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

លោកស្រីបានបញ្ជាក់ថា៖ «កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស កម្លាំងពលកម្មវ័យក្មេង និងការកែលម្អបរិយាកាសធុរកិច្ចរបស់កម្ពុជា បានធ្វើឱ្យប្រទេសនេះក្លាយជាគោលដៅកាន់តែទាក់ទាញ សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគរបស់អូស្ត្រាលី។ ក្រុមហ៊ុនអូស្ត្រាលីបាននិងកំពុងរួមចំណែកដល់ការអភិវឌ្ឍន៍របស់កម្ពុជា តាមរយៈបណ្តាវិស័យនានា រួមទាំងវិស័យកសិកម្មផងដែរ។ តាមរយៈគំនិតផ្តួចផ្តើមនានា ដូចជាបេសកកម្មផ្សារភ្ជាប់វិស័យកសិកម្ម និងអាហារនេះ យើងកំពុងជួយឱ្យធុរកិច្ចអូស្ត្រាលីស្វែងយល់កាន់តែច្បាស់អំពីទីផ្សារកម្ពុជា និងកសាងភាពជាដៃគូដែលគាំទ្រដល់កំណើនសេដ្ឋកិច្ចរយៈពេលវែង សម្រាប់ប្រទេសទាំងពីរ»។

បន្តពីសកម្មភាពនៅថ្ងៃនេះ ស្ថានទូតអូស្ត្រាលី នឹងរៀបចំ "វេទិកាកសិកម្ម និងអាហារ អូស្ត្រាលី-កម្ពុជា ឆ្នាំ២០២៦ ៖ ការធ្វើធុរកិច្ចនៅកម្ពុជា និងឱកាសវិនិយោគ" ដោយប្រមូលផ្តុំអ្នកជំនាញ តំណាងធុរកិច្ច និងរដ្ឋាភិបាល ដើម្បីពិភាក្សាអំពីកាលានុវត្តភាពវិនិយោគ និងភាពជាដៃគូ នៅទូទាំងខ្សែច្រវាក់តម្លៃកសិកម្ម និងអាហារ។ វេទិកានេះនឹងផ្តល់នូវការយល់ដឹងជាក់ស្តែងអំពីបទប្បញ្ញត្តិ និងទិដ្ឋភាពទីផ្សាររបស់កម្ពុជា គំរូវិនិយោគថ្មីៗ និងកិច្ចសហការយុទ្ធសាស្ត្រ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគីឱ្យកាន់តែស៊ីជម្រៅ។ បន្ទាប់មកបេសកកម្មផ្សារភ្ជាប់វិស័យកសិកម្ម និងអាហារអូស្ត្រាលី នឹងបន្តទៅកាន់ប្រទេសវៀតណាមនៅចុងសប្តាហ៍នេះ ដើម្បីបន្តជំរុញភាពជាដៃគូពាណិជ្ជកម្ម និងពង្រឹងការប្តេជ្ញាចិត្តយូរអង្វែងរបស់អូស្ត្រាលី ចំពោះវិបុលភាពរួម និងសន្តិសុខស្បៀងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

**សម្រាប់ព័ត៌មានបន្ថែម៖**

**ស្ថានទូតអូស្ត្រាលី:** Media.Cambodia@dfat.gov.au